# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** : ០៣០/១៥ **ក.ប/ស.ជ.៣**

## សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារបានជ្រាបថា កន្លងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្កេតឃើញថា នៅមានម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានមួយចំនួនបានដាក់ឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោងច្រើនពេកបណ្តាលឱ្យសុខភាពកម្មករនិយោជិតចុះខ្សោយ ហើយបង្កឱ្យមានគ្រោះថ្នាក់ការងារកើតឡើងជាញឹកញាប់។ ដើម្បីថែរក្សានិរន្តរភាព នៃកម្លាំងពលកម្ម បង្ការអំពីគ្រោះថ្នាក់ការងារដល់បងប្អូនកម្មករនិយោជិត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសូមក្រើនរំលឹកដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់ត្រូវអនុវត្តដូចតទៅ៖

១- ក្នុងករណីដែលម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានមានការងារច្រើនខុសធម្មតា ដែលតម្រូវឱ្យមានការធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតា ម្ចាស់ ឬនាយករោងចក្រ សហគ្រាសត្រូវស្នើសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមុនសិន។ នៅពេលទទួលបានការអនុញ្ញាតទើប ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន អាចរៀបចំធ្វើការបន្ថែមម៉ោងនេះបាន។ ការធ្វើការបន្ថែមម៉ោងនេះគឺអនុញ្ញាតឱ្យតែ ២ម៉ោងទេ ក្នុងមួយថ្ងៃ ហើយថិរវេលាធ្វើការ មិនត្រូវឱ្យលើសពីដប់ម៉ោងទេ ក្នុងមួយថ្ងៃ។

២- ការរៀបចំធ្វើការបន្ថែមម៉ោងត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត។

៣- ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន មិនត្រូវឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោងលើសពីការអនុញ្ញាតរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឡើយ។ ទោះបីមានការស្ម័គ្រចិត្តពីបងប្អូនកម្មករនិយោជិតក៏ដោយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងចាត់វិធានការតឹងរឹងបំផុតទៅតាមច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋាននានាដែលមានជាធរមាន ចំពោះម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានដែលប្រព្រឹត្តល្មើសលើចំណុចដែលបានរៀបរាប់ខាងលើនៃសេចក្តីជូនដំណឹងនេះ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីសង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះបានល្អប្រសើរ និងត្រឹមត្រូវជាពុំខាន។

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក
- សមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC)
  "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩